# ជំនួយបន្ថែមបន្តិចទៀត

ដោយ ជេន ម៉ាកប្រាយដ៍
( ផ្អែកទៅលើដំណើររឿងពិត )



ភ្អឹងដាយណូស័រស្ដាប់ទៅវាសប្បាយជាង
ការព្យាបាលការនិយាយទៅទៀត ។

កញ្ញា ជេនគីនបាននិយាយថា « អាទ្បិច ដល់ពេលដែលត្រូវទៅព្យាបាលការនិយាយហើយ » ។

អាទ្បិចបានឱនក្បាលគាត់ចុះ ។ ការព្យាបាលការនិយាយគឺជាថ្នាក់ពិសេសមួយដែលគាត់ចូលរួម ។ គាត់ពិបាកបញ្ចេញសំទ្បេងពាក្យមួយចំនួន ។ ដូច្នេះគាត់ត្រូវហាត់និយាយវាក្នុងថ្នាក់រៀន
និយាយពីរបីដងក្នុងមួយសប្ដាហ៍ ។ គ្រប់ពេលដែលគាត់ចេញពីថ្នាក់រៀនធម្មតារបស់គាត់ គាត់ខ្មាស់អៀនខ្លាំងណាស់ !

គាត់បានសំទ្បឹងមើលគ្រូរបស់គាត់ ។ គាត់បានខ្សឹបថា « តើខ្ញុំអាចសុំឈប់បានទេ ? » តែថ្ងៃនេះប៉ុណ្ណោះ ? »

ថ្ងៃនេះ លោក ចឹមមុនបានមកថ្នាក់របស់អាទ្បិចដើម្បីនិយាយអំពីដាយណូស័រ ។ លោក ចឹមមុនធ្វើការនៅសារមន្ទីរដែលមានភ្អឹងដាយណូស័រអស្ចារ្យជាច្រើន ។ គាត់ថែមទាំងយកភ្អឹងដែលមានអាយុកាលរាប់ពាន់ឆ្នាំមកជាមួយទៀតផង ! អាទ្បិចមិនចង់បាត់បង់ឱកាសនេះទ្បើយ ។

កញ្ញាជេនគីសបានញញឹម ។ « ប្អូននៅតែត្រូវទៅថ្នាក់ហាត់និយាយរបស់ប្អូនដដែល ។ ប៉ុន្តែប្អូនអាចមកទាន់ពេលសម្រាប់វគ្គចុងក្រោយនៃការសន្ទនាកថារបស់លោកចឹមមុន » ។

អាទ្បិចខំញញឹមតបទៅវិញទាំងពិបាក ។ គាត់បានដើរយឺតៗទៅកាន់ថ្នាក់ព្យាបាលការនិយាយ ។ នៅក្នុងថ្នាក់ពួកគេបានហាត់និយាយសំទ្បេងដដែលម្ដងហើយម្ដងទៀត ។ ការរៀនអំពីដាយណូស័រប្រហែលជាសប្បាយជាង ។

គាត់បានប្រាប់គ្រូព្យាបាលការនិយាយរបស់គាត់ថា « ខ្ញុំស្អប់សម្លេងភ្លតៗទាំងនេះណាស់ » ។ ខ្ញុំមានអារម្មណ៍ដូចជាកូនក្មេងអីចឹង » ។

នាងបាននិយាយថា « ប្អូនមិនមែនជាកូនក្មេងទេ » ។ ពេលខ្លះ យើងគ្រប់គ្នាត្រូវការជំនួយតិចតួចបន្ថែមទៀត ។ តើប្អូនដឹងទេថា អ្នកគ្រូមានការព្យាបាលការនិយាយពេលអ្នកគ្រូមានវ័យស្របាលប្អូន ? »

ការណ៍នោះបានធ្វើឲ្យអាទ្បិចធូរចិត្តបន្តិច ។ គាត់បានខំហាត់ធ្វើសំទ្បេងរបស់គាត់សម្រាប់ម៉ោងដែលនៅសល់ក្នុងថ្នាក់ ។

ពេលអាទ្បិចត្រទ្បប់ទៅថ្នាក់កញ្ញាជេនគីនវិញ គាត់បានឃើញមិត្តរបស់គាត់ឈ្មោះឃតនីកំពុងដើរចេញទៅ ។

គាត់បានសួរថា « តើឯងទៅណាហ្នឹង ? »

ឃតនីបានឈ្ងោកមុខចុះ ។ « ខ្ញុំមានបញ្ហាជាផ្នែកការអាន ។ ខ្ញុំត្រូវទៅថ្នាក់ពិសេសមួយដើម្បីរៀនអាន » ។
ឃតនីហាក់ដូចជាខ្មាស់អៀន ។

អាទ្បិចបាននិយាយថា « វាមិនអីទេ » ។ ខ្ញុំទើបតែត្រទ្បប់មកពីថ្នាក់រៀននិយាយរបស់ខ្ញុំដែរ ។ ខ្ញុំបានចំណាយនៅក្នុងថ្នាក់នោះធ្វើសំទ្បេងដដែលៗម្ដងហើយម្ដងទៀត » ។ គាត់បានធ្វើមុខជូរ ។

« មែនក៏អី ? »

គាត់បានងក់ក្បាល ។ « ខ្ញុំបានទៅថ្នាក់ព្យាបាលការនិយាយពីរឆ្នាំហើយ » ។

នាងបានសួរថា « ហេតុអ្វីក៏ខ្ញុំមិនដឹង ? »

អាទ្បិចបានគ្រវីក្បាល ។ « ខ្ញុំមិនបានប្រាប់នរណាទេ ។ ខ្ញុំខ្លាចពួកគេសើចចំអកខ្ញុំ » ។

ឃតនីបាននិយាយថា « ខ្ញុំនឹងមិនសើចចំអក
ឯងទ្បើយ » ។ ខ្ញុំរីករាយដែលឯងត្រទ្បប់មកទាន់ពេលដើម្បីឃើញភ្អឹងដាយណូស័រ ។ វាពិតជាអស្ចារ្យណាស់ ! » គាត់បានយក់ដៃលា ។ « ខ្ញុំត្រូវទៅហើយ ។ ជួបគ្នាពេលក្រោយ » ។

មិនយូរប៉ុន្មានអាទ្បិចបានដឹងថា មិនមែនតែគាត់និងឃតនីប៉ុណ្ណោះទេដែលបានទៅរៀនថ្នាក់ផ្សេងទៀតនោះ ។ ចមមីបានទៅរៀនថ្នាក់មួយដើម្បីជួយគាត់រៀនជំនាញសង្គមឲ្យកាន់តែប្រសើរ ។ ហើយបេកាបានរៀនជាមួយនឹងគ្រូពិសេសម្នាក់ដើម្បីជួយឲ្យដៃនាងមានកម្លាំងក្រោយពីមានការឈឺចាប់មក ។

ឥឡូវនេះ អាទ្បិចបានមានអារម្មណ៍ល្អចំពោះថ្នាក់រៀននិយាយរបស់គាត់ ។ គាត់ចង់ជួយក្មេងផ្សេងទៀតឲ្យមានអារម្មណ៍ល្អដែរ ។ គាត់បានហាត់អានជាមួយឃតនី ហើយបាននិយាយនឹងចមមីពេលបរិភោគអាហារថ្ងៃត្រង់ ។ ពេលខ្លះមនុស្សគ្រប់គ្នាត្រូវការជំនួយតិចតួចបន្ថែមទៀត ហើយវាមិនអីទេ ! ●

*ដំណើររឿងនេះបានកើតទ្បើងនៅ ស.រ.អ. ។*







